ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ០៧/១១-ជូន គិចថាយល៍**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **សួង សុផល**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

១- **ភាគីនិយោជក**

ឈ្មោះ : **ក្រុមហ៊ុន ជូន គិចថាយល៍**

អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៥៤១ ៨៥១ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- លោក ម៉េង គ្រី រដ្ឋបាល

២- លោក តាំង គីសាយ រដ្ឋបាល

២- **ភាគីកម្មករនិយោជិត**

ឈ្មោះ : - **សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា**

- **សហជីពសេរីកម្មករ នៃក្រុមហ៊ុន ជូន គិចថាយល៍**

អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០៨៨ ៨៣៣ ៥៥៥៥ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត: **អវត្តមាន**

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

កម្មករនិយោជិតនៅតែទាមទារសុំឱ្យក្រុមហ៊ុនតម្លើងតម្លៃបុង ដូចខាងក្រោម៖

- លេខរៀងទី១ (ដេរផ្លាកចំហៀង) ពីតម្លៃ ០,០៣ ដុល្លារ ទៅតម្លៃ ០,០៤ ដុល្លារ
- លេខរៀងទី៦ (ផ្ទុងមូកក្នុង និងភ្ជាប់មូក) ពីតម្លៃ ០,១០ ដុល្លារ ទៅតម្លៃ ០,១២ ដុល្លារ
- លេខរៀងទី១៣ (គូសហោប៉ៅ) ពីតម្លៃ ០,០៣ ដុល្លារ ទៅតម្លៃ ០,០៤ ដុល្លារ
- លេខរៀងទី១៧ (បញ្ចូលដៃ) ពីតម្លៃ ០,១០ ដុល្លារ ទៅតម្លៃ ០,១២ ដុល្លារ
- លេខរៀងទី៣២ (ភ្ជាប់មូក) ពីតម្លៃ ០,១២ ដុល្លារ ទៅតម្លៃ ០,១៤ ដុល្លារ
- លេខរៀងទី៣៣ (ផ្ទុងក) ពីតម្លៃ ០,០៦ ដុល្លារ ទៅតម្លៃ ០,០៧ ដុល្លារ
- លេខរៀងទី៣៧ (ភ្ជាប់ក) ពីតម្លៃ ០,១១ ដុល្លារ ទៅតម្លៃ ០,១២ ដុល្លារ

ដោយឡែកភាគីនិយោជកបញ្ជាក់ថា ពុំអាចផ្តល់ជូនតាមការទាមទារខាងលើបានទេ គឺសុំអនុវត្តតាមគោលការណ៍ចាស់ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៣ កប/ប្រក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ (អាណត្តិទី៨) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ០៣៩ កប/អក/វក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១១។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** : ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទប្រជុំមុនសវនាការ** : ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ (វេលាម៉ោង ១៤:០០ នាទី រសៀល) ។

**កាលបរិច្ឆេទសវនាការ** : ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១១ (វេលាម៉ោង ១៤:០០ នាទី រសៀល) ។

**បញ្ហានៃនីតិវិធី៖**

នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារ បានទទួលបណ្តឹងតាមទូរស័ព្ទពីក្រុមហ៊ុន ជូនតិចថាយ ស្តីពីកម្មករនិយោជិតក្រុម ៨ ធ្វើកូដកម្ម ទាមទារសុំតម្លើងតម្លៃបុង។ បន្ទាប់ពីបានទទួលបណ្តឹងនេះ នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារដល់ទីតាំងក្រុមហ៊ុន ដោយទទួលបាន លទ្ធផលមិនសះជានឹងគ្នាចំនួន ០១ ចំណុច លើការទាមទារចំនួន ០១ ចំណុច។ ចំណុចមិនសះជាចំនួន ០១ ចំណុច នេះ បានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១១។

រហូតមកដល់ថ្ងៃ ដែលលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលសំណុំរឿង លេខាធិការដ្ឋានបាន ទទួលដំណឹងថា កម្មករនិយោជិតនៅក្នុងក្រុមទី៨ ដែលទាមទារចំណុចវិវាទខាងលើនេះ កំពុងធ្វើកូដកម្មនៅកន្លែង ការងាររបស់ពួកគេ។ ដូចនេះ បន្ទាប់ពីក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើត ក្រុមអាជ្ញាកណ្តាលបានចេញសេចក្តី បញ្ជាមួយលេខ ០០១/១១ កបអ. ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ដើម្បីឱ្យកម្មករនិយោជិតក្នុងក្រុម ៨ នេះ ផ្អាកការធ្វើកូដកម្ម រង់ចាំនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលបញ្ចប់។ ប៉ុន្តែភាគីកម្មករនិយោជិតមិនបានគោរព តាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះទេ។ ដូចនេះ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ ក្រុមប្រឹក្សា អាជ្ញាកណ្តាលបានឱ្យលេខាធិការដ្ឋានកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកចូលរួមប្រជុំ ដើម្បី សាកសួរព័ត៌មានស្តីពីការធ្វើកូដកម្មរបស់ក្រុមទី៨នេះ នាថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ វេលាម៉ោង ១៤:00 នាទីរសៀលនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។ នៅក្នុងពេលប្រជុំនោះ ភាគីនិយោជកមានវត្តមានតាមការអញ្ជើញ រីឯ ភាគីសហជីពកម្មករនិយោជិតអវត្តមាន។ នៅពេលដែលលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការទំនាក់ ទំនងអំពីការចូលរួមប្រជុំមុនសវនាការនេះ ភាគីកម្មករនិយោជិតបានអះអាងថា កម្មករនិយោជិតនៅក្នុងក្រុមទី ៨ នេះ បានចូលធ្វើការជាធម្មតាវិញហើយ។

បន្ទាប់ពីបានទទួលព័ត៌មានពីការត្រឡប់ចូលធ្វើការរបស់កម្មករនិយោជិតក្នុងក្រុមទី៨នេះមក ក្រុមប្រឹក្សា អាជ្ញាកណ្តាលបានឱ្យលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករ និយោជិតប្រចាំរោងចក្រ មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០១ ចំណុចនេះ នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១១ វេលាម៉ោង ១៤:00 នាទីរសៀល។ ប៉ុន្តែ ភាគីកម្មករនិយោជិតមិនបានមកចូលរួមសវនាការ ហើយក៏មិនបានបញ្ជាក់ពីមូលហេតុ ឬស្នើសុំពន្យាពេលសវនាការ ដោយបញ្ជាក់ពីមូលហេតុត្រឹមត្រូវណាមួយ ឡើយ ដោយគ្រាន់តែបញ្ជាក់ថា មិនមកចូលរួមសវនាការអាជ្ញាកណ្តាលទេ។ ចំណែកឯភាគីនិយោជកវិញបាន មកចូលរួមសវនាការតាមការកោះហៅរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញា កណ្តាលនឹងធ្វើការពិចារណា និងសម្រេចលើចំណុចវិវាទក្នុងសំណុំរឿងនេះដូចខាងក្រោម ៖

THE ARBITRATION COUNCIL

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតលេខ ៨៦០ កប/អក/វក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ របស់ប្រធាននាយកដ្ឋានវិវាទការងារ ជំរាបមក លោកនាយកក្រុមហ៊ុន ជូន តិចថាយល៏ ស្តីពីការចាត់តាំងបុគ្គលិកទំនាក់ទំនងរបស់ក្រុមហ៊ុន។

២- លិខិតប្រគល់សិទ្ធិរបស់នាយករដ្ឋបាលក្រុមហ៊ុន ជូន តិចថាយល៏ ប្រគល់សិទ្ធិជូនលោក ម៉េង គ្រី និង លោក តាំង គីសាយ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១។

៣- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន ជូន តិចថាយល៏ លេខ ៣៨២៣ ពណ.ចបព ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៨។

៤- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ជូន តិចថាយល៏ ចុះបញ្ជិកាលេខ ០២៧ សកអ.អក ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៩៨។

៥- លក្ខន្តិកៈក្រុមហ៊ុន ជូន តិចថាយល៏ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៤។

៦- ឯកសារជាភាសារបរទេសមួយចំនួន។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត : គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ជូន តិចថាយល៏ លេខ ០៣៩ កប/អក/វក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ជូន តិចថាយល៏ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ ២០១១។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតលេខ ០៣៧ កប/អក/វក/លកអ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១១ របស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ជំរាបមក លោកប្រធានសហជីពសេរីកម្មករ នៃក្រុមហ៊ុន ជូន តិចថាយល៏ ស្តីពីការជ្រើសរើសអាជ្ញាកណ្តាល។

២- កំណត់ហេតុស្តីពីការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្តាល ពីបញ្ជីអាជ្ញាកណ្តាលស្នើដោយសហជីពកម្មករនិយោជិត ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១។

THE ARBITRATION COUNCIL

៣- សេចក្តីបញ្ជោរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០០១/១១ កបអ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ ២០១១។

៤- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័ត៌មាន លេខ ០៤៣ កប/អក/វក/លកអ. ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១។

៥- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមផ្តល់ព័ត៌មាន លេខ ០៤៤ កប/អក/វក/លកអ. ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១១។

៦- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ០៥១ កប/អក/វក/លកអ. ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១។

៧- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ០៥២ កប/អក/វក/លកអ. ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១។

**អង្គហេតុ** : គ្មាន

**ហេតុផលនៃសេចក្តីសម្រេចៈ**

នៅក្នុងសំណុំរឿងនេះ ភាគីសហជីព និងកម្មករនិយោជិត មិនបានចូលរួមសវនាការនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយភាគីកម្មករនិយោជិតបានបញ្ជាក់ប្រាប់ថា មិនមកចូលរួមសវនាការអាជ្ញាកណ្តាលទេ នៅពេលដែលលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ទំនាក់ទំនងតាមរយៈទូរសព្ទមុនថ្ងៃសវនាការ និងរំលឹកឱ្យចូលរួមសវនាការនៅថ្ងៃសវនាការក៏ដោយ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើសំណុំរឿងនេះ ដូចខាងក្រោមៈ

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ប្រសិនបើភាគីណាមួយមិនបានមកបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញសេចក្តីបង្គាប់"*។

ប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ប្រការ ២១ ចែងថា *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេល ដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញសេចក្តីបង្គាប់"*។

នៅក្នុងសំណុំរឿងលេខ ១៦/០៧-ឡូទូសតី និងលេខ ២៧/០៧-អ៊ីម និង វៃ ៣ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានបកស្រាយប្រការ ២១ ខាងលើនេះថា មានលក្ខខណ្ឌបីដែលត្រូវបំពេញ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាល សម្រេចបិទសំណុំរឿងបាន *"លក្ខខណ្ឌទី១ : ភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ លក្ខខណ្ឌទី២ : ភាគី*

*មិនបានបង្ហាញខ្លួននៅក្នុងសវនាការ និងលក្ខខណ្ឌទី៣ : ភាគីមិនបានផ្ដល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន* ”។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្ដាលក្នុងសំណុំរឿងមុនៗខាងលើដែរ។ ហេតុនេះហើយ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងពិចារណាថា តើលក្ខខណ្ឌទាំងបីនេះ ត្រូវបានបំពេញដែរ ឬទេ?

**លក្ខខណ្ឌទី១ : ភាគីត្រូវបានជូនដំណឹងត្រឹមត្រូវ**

មន្ត្រីលេខធិការដ្ឋានបានទំនាក់ទំនងទៅកាន់ភាគីកម្មករនិយោជិត ជូនដំណឹងពីសវនាការអាជ្ញាកណ្ដាល ប៉ុន្តែភាគីកម្មករនិយោជិតបានបញ្ជាក់ថា មិនមកចូលរួមសវនាការទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា ភាគីពិតជាទទួលបានការអញ្ជើញត្រឹមត្រូវពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល ឱ្យចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិតប្រាកដមែន។ **ហេតុនេះ លក្ខខណ្ឌទី១ ត្រូវបានបំពេញ។**

**លក្ខខណ្ឌទី ២ : ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ**

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា *“ពាក្យបង្ហាញខ្លួនក្នុងសវនាការ”* ប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាលនេះ មានន័យថា ភាគីត្រូវតែមាន (១) វត្តមាននៅក្នុងសវនាការ និង (២) ចូលរួមដំណើរការសវនាការអាជ្ញាកណ្ដាលរហូតចប់សព្វគ្រប់។

ដំណើរការអាជ្ញាកណ្ដាលមានបួនដំណាក់កាល ដូចជា:

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាលផ្សះផ្សាឡើងវិញ

ឃ-និងដំណាក់កាលសវនាការដល់អង្គសេចក្ដី

ក្នុងករណីនេះ ភាគីសហជីព និងកម្មករនិយោជិត មិនបានចូលរួមគ្រប់ដំណាក់កាលទាំងបួនខាងលើនេះ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ភាគីសហជីព និងកម្មករនិយោជិត មិនបានបង្ហាញខ្លួននៅក្នុងសវនាការតាមខ្លឹមសារនៃលក្ខខណ្ឌទី២ នៃប្រការ ២១ ខាងលើនេះទេ។ **ហេតុនេះហើយ លក្ខខណ្ឌទី២ ក៏ត្រូវបានបំពេញដែរ។**

**លក្ខខណ្ឌទី៣ : ភាគីមិនបានផ្ដល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន**

ក្នុងករណីនេះ ភាគីសហជីព និងកម្មករនិយោជិត មិនបានផ្ដល់ហេតុផលណាមួយសម្រាប់ការមិនចូលរួមសវនាការនេះទេ ពីព្រោះមកដល់ថ្ងៃសវនាការ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១១ វេលាម៉ោង ១៥:00 នាទីរសៀល លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានធ្វើទំនាក់ទំនងតាមទូរសព្ទរំលឹកទៅភាគីនិយោជក និងភាគីសហជីព

អំពីសវនាការអាជ្ញាកណ្តាល ។ ភាគីកម្មករនិយោជិតបានឆ្លើយថា ភាគីកម្មករនិយោជិតមិនមកចូលរួមសវនាការនេះទេ ហើយទុកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចតាមនីតិវិធីចុះ ។ ចំណែកឯភាគីក្រុមហ៊ុនបានអញ្ជើញមកចូលរួមក្នុងសវនាការតាមកាលកំណត់ ។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា **ភាគីសហជីព និងកម្មករនិយោជិតមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួននេះទេ ។ ហេតុនេះហើយ លក្ខខណ្ឌទី៣ ក៏ត្រូវបានបំពេញដែរ ។**

ដូច្នេះ ជាសរុបមក លក្ខខណ្ឌទាំងបី ដែលមានចែងក្នុងប្រការ២១ ខាងលើ ត្រូវបានបំពេញ ។

ផ្អែកតាមវិធាន និងប្រកាស ព្រមទាំងការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ទោះបីភាគីសហជីព និងកម្មករនិយោជិត មិនចូលរួមក្នុងដំណើរការអាជ្ញាកណ្តាល ក៏ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអំណាចក្នុងការចេញសេចក្តីបង្គាប់ដែរ ។

បន្ថែមពីលើនេះទៀត នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានផ្តល់ឱកាសគ្រប់គ្រាន់ដល់សហជីពសេរីកម្មករនៃរោងចក្រ ជូន តិចថាយល៍ ដែលជាភាគីដើមបណ្តឹងក្នុងការធ្វើការការពារចំពោះការទាមទាររបស់កម្មករនិយោជិតដែលពឹងពាក់ខ្លួនតាមនីតិវិធីច្បាប់ស្តីពីការងារ ។ ប៉ុន្តែ ភាគីកម្មករនិយោជិតបានជ្រើសរើសការមិនចូលរួមសវនាការ និងបោះបង់ឱកាសក្នុងការបង្ហាញភស្តុតាង ដើម្បីគាំទ្រការទាមទាររបស់ខ្លួនទៅវិញ ។ ជាទូទៅ ដើមបណ្តឹងមានកាតព្វកិច្ចផ្តល់ហេតុផល និងភស្តុតាងនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីការពារបណ្តឹងរបស់ខ្លួន។ ប៉ុន្តែក្នុងសំណុំរឿងនេះ ភាគីសហជីព និងកម្មករនិយោជិត ដែលជាភាគីដើមបណ្តឹងមិនបានផ្តល់នូវហេតុផល និងភស្តុតាង ដើម្បីការពារបណ្តឹងរបស់ខ្លួនទេ។ ក្នុងករណី ភាគីដើមបណ្តឹងមិនចូលរួមក្នុងសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើឱ្យភាគីបាត់បង់ឱកាសក្នុងការផ្តល់ហេតុផល និងភស្តុតាង ដើម្បីការពារ និងគាំទ្រការទាមទាររបស់ខ្លួន។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា នេះជាការបោះបង់បណ្តឹងរបស់ខ្លួន។ ការសម្រេចចិត្តបែបនេះ គឺមិនបានបង្ហាញពីសុឆន្ទៈ ដោយសុទ្ធចិត្តរបស់ភាគីកម្មករនិយោជិត ក្នុងការយកវិវាទការងាររបស់ខ្លួនមកដោះស្រាយនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះឡើយ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបិទសំណុំរឿងលេខ ០៧/១១-ជូន តិចថាយល៍នេះ ។

យោងតាមហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចដូចតទៅ :

## សម្រេច និង បង្គាប់

សម្រេចបិទសំណុំរឿងលេខ ០៧/១១-ជូន តិចថាយល៍ ។

## ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :**

ឈ្មោះ : **អ៊ឹង សុទ្ធី**

ហត្ថលេខា: ------------------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :**

ឈ្មោះ : **សួន សុផល**

ហត្ថលេខា: ------------------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល :**

ឈ្មោះ : **ប៉ែន ម៉ុនឈា**

ហត្ថលេខា: ------------------------------------------